# ស្ថានភាពអតិផរណានៅខែមេសា ឆ្នាំ២០១៧

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែមេសា ឆ្នាំ២០១៧ មានការកើនឡើង **០,៤%** ធៀបនឹងខែមុនឬ **៣,២%** បើធៀបនឹង១២ខែមុន។

សន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួនមានកើនឡើងគួរឱ្យកត់សម្គាល់ធៀបនឹងខែមីនា ដូចជាសន្ទស្សន៍អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង បានកើនឡើង០,៦% ដែលបណ្តាលមកពីការកើនឡើងថ្លៃសាច់ជ្រូក ត្រីនិងបន្លែ។ សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹមសម្ភារៈប្រើប្រាស់ និងថែទាំបានកើនឡើង១,០% សន្ទស្សន៍ថ្លៃភោជនីយដ្ឋានកើនឡើង០,៧% និងសន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និងស្បែកជើងបានកើនឡើង ០,៥%។

បើធៀបនឹង១២ខែមុន សន្ទស្សន៍ថ្លៃទំនិញសរុបមានការកើនឡើង**៣,២%** ដែលបណ្តាលមកពីថ្លៃសាច់ជ្រូកកើនឡើង៣,៨% ថ្លៃសាច់គោកើនឡើង៣,២% ថ្លៃសាច់មាន់កើនឡើង៣,៥% ថ្លៃត្រីកើនឡើង៨,៤% និងថ្លៃបន្លែកើនឡើង៥,៤%, សន្ទស្សន៍ថ្លៃការដឹកជញ្ជូនកើនឡើង៥,៩% ក្នុងនោះថ្លៃប្រេងសាំងធម្មតានិងប្រេងម៉ាស៊ូតកើនឡើង ១៥,៥% និង១២,៦%, និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋានកើនឡើង ៤,១%។

តាមការធ្វើចំណោលគិតដល់ត្រឹមខែធ្នូ ឆ្នាំ២០១៧ អតិផរណាប្រចាំឆ្នាំ (year on year) អាចមានអត្រា ២,៧% ឬ អតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចមានអត្រា ៣,៤%។

| **តារាង ១÷ ការប្រែប្រួលសន្ទស្សន៍ថ្លៃទាំង១២ ក្រុម មានដូចខាងក្រោម÷** | | |
|---|---|---|
| | **ធៀបខែមុន** | **ធៀប១២ខែមុន** |
| **មុខទំនិញគ្រប់មុខ** | **០,៤** | **៣,២** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | ០,៦ | ៣,៨ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ០,០ | ៣,១ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | ០,៥ | ២,៧ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ០,១ | ០,៤ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | ១,០ | ២,៦ |
| ៦-សុខាភិបាល | -០,២ | ១,២ |
| ៧-ការដឹកជញ្ជូន | ០,០ | ៥,៩ |
| ៨-គមនាគមន៍ | -០,៤ | -០,៧ |
| ៩-ការកំសាន្ត និងវប្បធម៌ | -០,៨ | ១,៦ |
| ១០-ការសិក្សា | ០,០ | ០,០ |
| ១១-ភោជនីយដ្ឋាន | ០,៧ | ៤,១ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | ០,៥ | ០,៤ |

| តារាង ២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ (%) | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន | | | | ធៀបនឹង១ឆ្នាំមុន | | | |
| | ២០១៧ | | | | ២០១៧ | | | |
| | មករា | កុម្ភៈ | មីនា | មេសា | មករា | កុម្ភៈ | មីនា | មេសា |
| អង្ករ | -០,៥ | ០,៣ | ០,១ | ០,១ | ២,៦ | ២,៩ | ៣,២ | ២,៣ |
| សាច់គោ | ០,៣ | ០,០ | ០,០ | ០,០ | ៦,១ | ៤,៤ | ៤,០ | ៣,២ |
| សាច់មាន់ | ០,៩ | -០,៤ | -០,៩ | ០,៧ | ៨,៤ | ៦,០ | ៤,៥ | ៣,៥ |
| សាច់ទា | ០,១ | -០,៧ | ០,២ | -០,៤ | ១,៧ | ០,៧ | ១,៨ | ០,៥ |
| សាច់ជ្រូក | ០,៥ | -០,២ | ០,១ | ១,១ | ៤,៦ | ៣,២ | ៣,៥ | ៣,៨ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | ០,០ | ០,៥ | -០,២ | ១,១ | ៩,៦ | ១០,០ | ៩,០ | ៧,៩ |
| ក្នុងនោះត្រីស្រស់ | ០,២ | ០,៥ | -០,១ | ១,០ | ១០,១ | ១០,៧ | ១០,១ | ៨,៤ |
| ផ្លែឈើ | ០,៦ | -០,១ | ០,៥ | -០,៥ | ៦,២ | ៣,៩ | ៥,២ | -០,៨ |
| ផ្លែឈើស្រស់ | ០,៦ | ០,០ | ០,៥ | -០,៤ | ៦,៤ | ៤,២ | ៦,០ | -០,៩ |
| បន្លែ | ០,៣ | -០,៦ | -០,៩ | ១,១ | ១៥,៧ | ១៣,២ | ១១,៨ | ៥,៤ |
| បន្លែជាស្លឹក | -០,២ | -០,៨ | -១,៧ | ១,៤ | ១៦,៦ | ១៤,៣ | ១០,១ | ៦,៩ |
| បន្លែជាផ្លែ | ១,២ | -១,៦ | -០,៩ | ១,០ | ២៦,១ | ២០,៧ | ២១,៧ | ៤,៦ |

## ២/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង៣÷ អតិផរណាប្រចាំឆ្នាំ (%) | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៦ | | | | ២០១៧ | | | |
| | មករា | កុម្ភៈ | មីនា | មេសា | មករា | កុម្ភៈ | មីនា | មេសា |
| ប្រទេសកម្ពុជា | 3.0 | 2.3 | 2.03 | 2.8 | 4.4 | 4.0 | 4.3 | 3.2 |
| ប្រទេសវៀតណាម | 0.8 | 1.3 | 1.69 | 1.89 | 5.2 | 5.0 | 4.7 | 4.3 |
| ប្រទេសថៃ | -0.5 | -0.5 | -0.46 | 0.07 | 1.6 | 1.4 | 0.76 | 0.38 |
| ប្រទេសម៉ាឡេស៊ី | 3.5 | 4.2 | 2.61 | 2.14 | 3.2 | 4.5 | 5.1 | 4.4 |
| ប្រទេសឥណ្ឌូនេស៊ី | 4.1 | 4.4 | 4.45 | 3.60 | 3.5 | 3.8 | 3.6 | 4.2 |
| ប្រទេសហ្វីលីពីន | 1.4 | 0.9 | 1.13 | 1.10 | 2.7 | 3.3 | 3.4 | 3.4 |
| ប្រទេសចិន | 1.8 | 2.3 | 2.3 | 2.3 | 2.5 | 0.8 | 0.9 | 1.2 |
| ប្រទេសកូរ៉េខាងត្បូង | 0.8 | 1.2 | 0.97 | 1.01 | 2.0 | 1.9 | 2.2 | 1.9 |
| ប្រទេសជប៉ុន | -0.1 | 0.3 | 0.0 | -0.3 | 0.4 | 0.3 | 0.2 | 0.4 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត ពីគេហទំព័រ http://www.tradingeconomics.com;

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)
- ប្រភពទិន្នន័យ ពីក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំដោយនាយកដ្ឋានស្ថិតិ***

***អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ***

***ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***